ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន

លេខ:១៥១/ន.៣
១៦

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ រដ្ឋមន្ត្រីការពារជាតិនៃចក្រភពអង់គ្លេស **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាត** នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិ ស្តីពីការរក្សាសន្តិភាព ក្នុងក្របខណ្ឌរបស់អង្គការសហប្រជាជាតិចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ ។

កិច្ចប្រជុំនេះ នឹងប្រព្រឹត្តិទៅនាថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ នៅទីក្រុងឡុងដ៏ ដែលរៀបចំឡើងដោយក្រសួងការពារជាតិនៃចក្រភពអង់គ្លេសសហការជាមួយ អ.ស.ប ដែលមានប្រទេសចូលរួមចំនួនជិត៨០ប្រទេស ក្នុងនោះប្រទេសអាស៊ានមាន ០៦ប្រទេសគឺ: កម្ពុជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងវៀតណាម ។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់** ក៏នឹងបង្ហាញពីចក្ខុវិស័យរបស់កម្ពុជាក្នុងគោលដៅនិរន្តរភាពនៃការអភិវឌ្ឍន៍ថ្មីនៃការបញ្ជូនកងកម្លាំងរក្សាសន្តិភាពនាពេលអនាគត និងការប្តេជ្ញាចិត្តយ៉ាងមុតមាំលើវិស័យរក្សាសន្តិភាពក្នុងការបន្តចូលរួមបំពេញបេសកកម្មរបស់ អ.ស.ប ដើម្បីបន្តរួមវិភាគទានជាមួយសហគមន៍អន្តរជាតិ ក្នុងកិច្ចប្រឹងប្រែងស្វែងរកសន្តិភាពជូនប្រទេសដទៃ នៅលើពិភពលោកជាបន្តទៀត ។

ក្នុងអំឡុងពេលអញ្ជើញទៅបំពេញទស្សនកិច្ច ចូលរួមកិច្ចប្រជុំនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់** គ្រោងនឹងជួបពិភាក្សាការងារជាមួយ ឯកឧត្តម រដ្ឋមន្ត្រីការពារជាតិនៃចក្រភពអង់គ្លេស ផងដែរ ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦

នាយកដ្ឋានព័ត៌មាន